# នរណាជាពួកក្រុមជំនុំណាសារីន

យើងខ្ញុំសូមនាំអោយស្គាល់ក្រុមជំនុំណាសារីន

ក្រុមជំនុំបានរៀបចំកើតឡើងនៅថ្ងៃទី៨ ខែតុលា ឆ្នាំ១៩០៨ នៅ ផៃលុត ភញ់ (Pilot Point) រដ្ឋតិចសាស សហរដ្ឋអាមេរិក។ ក្រុមជំនុំណាសារីនបានដូរលំនៅមកក្រុងខិនសាស ស៊ីធី នៅរដ្ឋ មីសួរី (Kansas City, Mo.) នៅពេលយ៉ាងខ្លីបន្ទាប់ពីបានកើតឡើងជាគណៈនិកាយមក។ មជ្ឈមណ្ឌលអន្តរជាតិរបស់ក្រុមជំនុំស្ថិតនៅ 6401 The Paseo, Kansas City, Mo.

មជ្ឈមណ្ឌលអន្តរជាតិណាសារីនផ្តល់ការបំរើផ្គត់ផ្គង់ដល់សមាជិកចំនួន ១លាន៣សែននាក់ ដែលថ្វាយបង្គំព្រះនៅក្នុងក្រុមជំនុំជាង១១៨០០ នៅក្នុងសហរដ្ឋអាមេរិក ប្រទេស កាណាដា និង ប្រទេសចំនួន ១៤១ ទៀតនៅក្នុងពិភពលោក។

ប្រធានសំខាន់របស់គណៈនិកាយណាសារីនសំរាប់ឆ្នាំ ២០០១ ដល់២០០៥ គឺ "ព្រះ យេស៊ូវ . . . ជាទីសង្ឃឹមយ៉ាងឧត្តម" (កូល៉ុស ១:២៧)។ ប្រធាននេះសំដែងប្រាប់អំពីចំណង់ដ៏មមុលទៅមុខរបស់គណៈនិកាយដើម្បីចែកចាយដំណឹងល្អថាព្រះយេស៊ូវគ្រីស្ទជាប្រភពនៃសេចក្តីសង្ឃឹមសំរាប់ជីវិតយើង។

# មាត្រានៃគោលជំនឿ

## បរិបទ

ដើម្បីអោយយើងអាចរក្សាមរដកដែលព្រះទ្រង់បានប្រទានមក  គឺជាជំនឿដែលបានប្រទានដល់ពួកអ្នកបរិសុទ្ធម្តងរួចហើយ ជាពិសេសគឺគោលលិទ្ធិនិងការពិសោធន៍អំពីការញែកទាំងអស់ជាបរិសុទ្ធ ដែលជាកិច្ចការទី២នៃព្រះគុណ ហើយនិងការដែលយើងអាចចូលរួមសហការ ជាមួយនឹងសាខានៃក្រុមជំនុំព្រះយេស៊ូវគ្រីស្ទឯទៀតក្នុងការធ្វើអោយនគរព្រះរីកចំរើនទៅមុខទៀត ដោយយោងទៅតាមគោលការណ៏នៃមាត្រាច្បាប់ដែលបានតែងតាំងឡើងក្នុងចំណោមពួកយើង យើងទាំងអស់គ្នាដែលជាអ្នកបំរើកិច្ចការព្រះហើយនិងជាសមាជិកនៃក្រុមជំនុំណាសារីន ទទួលចាត់តាំង យល់ព្រម និងអនុវត្តទុកជាមូលដ្ឋានមាត្រាច្បាប់នៃក្រុមជំនុំណាសារីន នូវមាត្រានៃគោលជំនឿ ក្បួនទូទៅនិងមាត្រាសំរាប់អង្គការនិងអ្នកដឹកនាំ ដូចខាង ក្រោមនេះ :

## ១ ព្រះត្រីឯក

១ យើងជឿទៅលើព្រះតែមួយគង់នៅអស់កល្ប គ្មានកំរិត ជាមហាក្សត្រមានអំណាច គ្រប់គ្រងលើចក្រវាឡ គឺទ្រង់ហើយជាព្រះតែមួយគត់ ដែលមានប្រឌិតញាណនិងការគ្រប់គ្រង អភិបាលលើអ្វីទាំងអស់ បរិសុទ្ធក្នុងនិស្ស័យលក្ខណៈសម្បត្តិ និងគោលដៅ ដែលទ្រង់ក្នុងភាព ជាព្រះ ចែកជាបីអង្គដ៏សំខាន់ បានសំដែងចេញជាព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។

(លោកុប្បត្តិ ១, លេវីវិន័យ ១៩:២, ចោទិយកថា ៦:៤-៥, អេសាយ ៥:១៦, ៦:១-៧, ៤០:១៨-៣១, ម៉ាថាយ ៣:១៦-១៧, ២៨:១៩-២០, យ៉ូហាន ១៤:៦-២៧, កូរិនថូសទី១ ៨:៦, កូរិនថូសទី២ ១៣:១៤, កាឡាទី ៤:៤-៦, អេភេសូរ ២:១៣-១៨)។

## ២ ព្រះយេស៊ូវគ្រីស្ទ

យើងជឿទៅលើព្រះយេស៊ូវគ្រីស្ទ ជាតួអង្គទី២ក្នុងអង្គព្រះត្រីឯក ដែលទ្រង់គង់នៅអស់ កល្បជាព្រះតែមួយជាមួយនឹងព្រះវរបិតា ដែលព្រះអង្គបានមកចាប់កំណើតដោយសារព្រះវិញ្ញាណបរិសុទ្ធ ហើយបានប្រសូតិពីនាងម៉ារាជាក្រមុំព្រហ្មចារីយ ដើម្បីអោយនិស្ស័យទាំងពីរពេញលេញ ហើយគ្រប់លក្ខណ៍ ក្នុងភាពជាព្រះផងហើយនិងជាមនុស្សផងបានរួមមកជាតួព្រះតែមួយដ៏ពិត ហើយជាតួមនុស្សដ៏ពិត គឺជាព្រះផងជាមនុស្សផង។

យើងជឿថាព្រះយេស៊ូវបានសុគតសំរាប់បាបរបស់យើង ហើយថាទ្រង់បានរស់ពី សុគតឡើងវិញក្នុងរូបកាយទ្រង់ម្តងទៀត រួមជាមួយអ្វីទាំងអស់ដែលទាក់ទងទៅនឹងភាពគ្រប់លក្ខណ៏នៃនិស្ស័យជាមនុស្ស រួចហើយទ្រង់បានយាងនិវត្តទៅស្ថានសួគ៌វិញ ហើយគង់នៅទីនោះ ព្រះអង្គបានរវល់ជួយតវ៉ា សូមទោសជំនួសយើង។

(ម៉ាថាយ ១:២០-២៥, ១៦:១៥-១៦, លូកា ១:២៦-៣៥, យ៉ូហាន ១:១-១៨, កិច្ចការ ២:២២-៣៦, រ៉ូម ៨:៣, ៣២-៣៤, កាឡាទី ៤:៤-៥, ភីលិព ២:៥-១១, កូល៉ុស ១:១២-២២, ធីម៉ូថេទី១ ៦:១៤-១៦, ហេព្រើរ ១:១-៥, ៧:២២-២៨, ៩:២៤-២៨, យ៉ូហានទី១ ១:១-៣, ៤:២-៣, ៤:១៥)។

## ៣ ព្រះវិញ្ញាណបរិសុទ្ធ

៣ យើងជឿទៅលើព្រះវិញ្ញាណបរិសុទ្ធ ជាតួអង្គទី៣ក្នុងអង្គព្រះត្រីឯក ដែលព្រះអង្គតែង តែគង់នៅជាមួយ មានសកម្មភាពដោយប្រសិទ្ធិភាព ហើយរួមជាមួយនិងក្រុមជំនុំព្រះគ្រីស្ទ ធ្វើអោយមនុស្សក្នុងលោកីយជឿថាខ្លួនមានបាប អប់រំជាថ្មីដល់អ្នកដែលប្រែចិត្តហើយទទួលជឿ ញែកអ្នកជឿចេញជាបរិសុទ្ធ ហើយដឹកនាំទៅរកការពិតដែលនៅក្នុងព្រះយេស៊ូវគ្រីស្ទ។

យ៉ូហាន ៣:៣៩, ១៤:១៥-១៨, ១៥:២៦, ១៦:៧-១៥, កិច្ចការ ២:៣៣, រ៉ូម ៨:១-២៧, កាឡាទី ៣:១-១៤, ៥:៦, អេភេសូរ ៣:១៤-២១, ថែស្សាឡូនិចទី១ ៥:៧-៨, ថែស្សាឡូនិចទី២ ២:១៣, ពេត្រុសទី១ ១:២, យ៉ូហានទី១ ៣:២៤, ៥:១៣)។

## ៤ ព្រះបន្ទូលបរិសុទ្ធ

៤ យើងជឿទៅលើការបណ្តាលចិត្តដ៏ពេញលេញនៃព្រះបន្ទូលបរិសុទ្ធ តាមការយល់ ដឹងថាគម្ពីរទាំង៦៦កណ្ឌក្នុងសញ្ញាចាស់និងសញ្ញាថ្មី បានប្រទានមកដោយព្រះទ្រង់បានបណ្តាលចិត្តសំដែងចេញដោយឥតកន្លែងខុស នូវឆន្ទៈរបស់ព្រះចំពោះយើងនៅក្នុងគ្រប់អ្វីៗទាំងអស់ចាំបាច់ដល់សេចក្តីសង្គ្រោះរបស់យើង ដើម្បីអ្វីៗដែលមិនមាននៅក្នុងនោះមិនត្រូវឲ្យបានដំរូវទុកជាមាត្រានៃជំនឿទេ។

(លូកា ២៤:៤៤-៤៧, យ៉ូហាន ១០:៣៥, កូរិនថូសទី១ ១៥:៣-៤, ធីម៉ូថេទី២ ៣:១៥-១៧, ពេត្រុសទី១ ១:១០-១២, ពេត្រុសទី២ ១:២០-២១)

## ៥ បាបដើមដំបូងនិងបាបប្រព្រឹត្តផ្ទាល់

៥ យើងជឿថាបាបបានចូលមកក្នុងលោកីយនេះតាមរយៈការមិនស្តាប់បង្គាប់នៃមាតា បិតាដើមរបស់យើង ហើយនិងសេចក្តីស្លាប់បណ្តាលមកពីបាប។ យើងជឿថាបាបមាន២យ៉ាង: បាបដើមដំបូងឬភាពខូចបង់ ហើយនិងបាបពិតឬដែលប្រព្រឹត្តផ្ទាល់។

៥.១ យើងជឿថាបាបដើមដំបូងឬភាពខូចបង់ គឺជាការពុករលួយនៃនិស្ស័យរបស់ពូជ អាដាម គឺដោយហេតុនេះហើយបានជាគ្រប់គ្នាបានឃ្លាតចេញឆ្ងាយពីសេចក្តីសុចរិតដើមដំបូងឬភាពបរិសុទ្ធនៃ មាតាបិតដំបូងរបស់យើងនៅក្នុងពេលដែលព្រះបង្កើតឡើង  គឺប្រឆាំងនឹងព្រះ គ្មានជីវិតខាងវិញ្ញាណ ហើយងាកេទៅរកការអាក្រក់ ហើយចេះតែប្រព្រឹត្តជាបន្តតរហូតមក។ យើងជឿថែមទៀតថាបាបដើមដំបូងបន្តមានមកនៅក្នុងជីវិតថ្មីនៃអ្នកផ្លាស់ប្រែ រហូតទាល់តែចិត្តបានទទួលការលាងសំអាតពេញបរិបូរដោយព្រះវិញ្ញាណបរិសុទ្ធ។

៥.២ យើងជឿថាបាបដើមដំបូងខុសគ្នាពីបាបជាក់ស្តែងដែលបានប្រព្រឹត្តផ្ទាល់នៅក្នុង ការដែលបាបដើមដំបូងបានផ្សំកើតជាឧបនិស្ស័យតពូជរហូតដល់បាបជាក់ស្តែងដែលគ្មាននរណា ម្នាក់ត្រូវទទួលខុសត្រូវ ទាល់តែគេប្រកែកមិនព្រមទទួលឬមិនអើពើនឹងគលិកាដែលព្រះបាន ប្រទានមក។

៥.៣ យើងជឿថាបាបជាក់ស្តែងឬបាបដែលប្រព្រឹត្តផ្ទាល់គឺជាការរំលងដោយស្ម័គ្រពីចិត្ត ទៅលើច្បាប់ព្រះដែលបានដឹងស្គាល់ ដោយសារអ្នកដែលមានស្មារតីអាចទទួលខុសត្រូវណាម្នាក់។ ដូច្នេះ កុំអោយយល់ច្រឡំនឹងការមិនពេញខ្នាតដែលមិនអាចគេចរួចបាននិងមិនចេញពី ក្នុងចិត្ត ការជរាពិការ កំហុស ការខុសឆ្គង បរាជ័យ ឬការរេចេញពីខ្នាតនៃចរិយាគ្រប់លក្ខណ៍ ដែលជាផលសេស សល់ពីការធ្លាក់របស់មនុស្សពីដើមដំបូង។ តែទោះជាយ៉ាងណាក៏ដោយ ផលដែលឥត

ត្រូវមានទោសនេះមិនរាប់បញ្ចូលនូវអាកប្បកិរិយាឬការតបតប្រឆាំងនឹងព្រះវិញ្ញាណ ព្រះគ្រីស្ទ ដែលអាចហៅយ៉ាងត្រឹមត្រូវថាជាអំពើបាបនៃវិញ្ញាណ។ យើងជឿថាបាបដែលប្រព្រឹត្ត ផ្ទាល់គឺជាបឋមនិងសំខាន់បំផុតគឺជាការរំលងច្បាប់នៃសេចក្តីស្រឡាញ់ ហើយចំពោះព្រះគ្រីស្ទវិញ បាបអាចមានន័យថាការមិនទទួលជឿ។

(បាបដើមដំបូងៈ លោកុប្បត្តិ ៣, ៦:៥, យ៉ូប ១៥:១៤, ទំនុកដំកើង ៥១:៥, យេរេមា ១៧:៩-១០, ម៉ាកុស ៧:២១-២៣, រ៉ូម ១:១៨-២៥, ៥:១២-១៤, ៧:១ - ៨:៩, កូរិនថូសទី១ ៣:១-៤, កាឡាទី ៥:១៦-២៥, យ៉ូហានទី១ ១:៧-៨, បាបប្រព្រឹត្តផ្ទាល់ៈ ម៉ាថាយ ២២:៣៦-៤០, យ៉ូហានទី១ ៣:៤, យ៉ូហាន ៨:៣៤-៣៦, ១៦:៨-៩, រ៉ូម ៣:២៣, ៦:១៥-២៣, ៨:១៨-២៤, ១៤:២៣, យ៉ូហានទី១ ១:៩-២៤, ៣:៧-១០)

## ៦ សេចក្តីប្រោសលោះ

៦ យើងជឿថាព្រះយេស៊ូវគ្រីស្ទ ដោយសារការរងទុក្ខរបស់ទ្រង់ ដោយសារការបង្ហូរ ព្រះលោហិតទ្រង់ផ្ទាល់ និងដោយសារការសុគតរបស់ទ្រង់នៅលើឈើឆ្កាង បានរៀបជាការ ប្រោសលោះដ៏ពេញលេញសំរាប់បាបរបស់មនុស្សទាំងអស់ ហើយដែលការប្រោសលោះនេះ គឺជាមូលបទតែមួយគត់នៃសេចក្តីសង្គ្រោះ ហើយជាការគ្រប់គ្រាន់សំរាប់ជនរាល់គ្នាក្នុងពូជពង្សរបស់អាដាម។ ការប្រោសលោះមានប្រសិទ្ធិភាពដោយព្រះគុណសំរាប់សេចក្តីសង្គ្រោះដល់អ្នកដែលមិនអាចទទួលខុសត្រូវ ហើយនិងដល់កូនក្មេងតូចៗដែលនៅក្នុងភាពមិនទាន់ចេះធ្វើបាប ប៉ុន្តែមានប្រសិទ្ធិភាពសំរាប់សេចក្តីសង្គ្រោះដល់អ្នកមានអាយុអាចទទួលការខុសត្រូវបានគឺនៅតែក្នុងពេលដែលគេប្រែចិត្តហើយទទួលជឿតែប៉ុណ្ណោះ។

(អេសាយ ៥៣:៥-៦, ១១, ម៉ាកុស ១០:៤៥, លូកា ២៤:៤៦-៤៨, យ៉ូហាន ១:២៩, ៣:១៤-១៧, កិច្ចការ ៤:១០-១២, រ៉ូម ៣:២១-២៦, ៤:១៧-២៥, កូរិនថូសទី១ ៦:២០, កូរិនថូសទី២ ៥:១៤-២១, កាឡាទី ១:៣-៤, ៣:១៣-១៤, កូលុ៉ស ១:១៩-២៣, ធីម៉ូថេទី១ ២:៣-៦, ទីតុស ២:១១-១៤, ហេព្រើរ ២:៩, ៩:១១-១៤, ១៣:១២, ពេត្រុសទី១ ១:១៨-២១, ២:១៩-២៥, យ៉ូហានទី១ ២:១-២)

## ៧ ព្រះគុណដែលបានផ្តល់ទុកជាមុន

៧ យើងជឿថាការដែលព្រះបានបង្កើតមនុស្សគ្រប់សាសន៍ក្នុងរូបភាពព្រះ ដោយរួម បញ្ចូលទាំងសមត្ថភាពក្នុងការជ្រើសរើសការល្អនិងអាក្រក់ ហើយដែលមនុស្សជាតិត្រូវទទួលការខុសត្រូវក្នុងបែបចិត្តគំនិតដែលគេរស់នៅ ដែលតាមរយៈការធ្លាក់ចុះក្នុងបាបរបស់អាដាម គេបាន ខូចបង់រហូតដល់គេមិនអាចបែរចេញហើយរៀបចំខ្លួនគេតាមកំលាំងនិស្ស័យផ្ទាល់របស់គេនិងការប្រព្រឹត្តអោយបានជំនឿ ហើយស្រែកអំពាវនាវរកព្រះបានឡើយ។ ប៉ុន្តែ យើងក៏ជឿដែរថា

ព្រះគុណនៃព្រះតាមរយៈព្រះយេស៊ូវគ្រីស្ទបានប្រទានដល់មនុស្សទាំងអស់ដោយឥតដំរូវអ្វី ជាជំនួយដល់អស់អ្នកណាដែលនឹងជឿអាចបែរពីបាបមករកសេចក្តីសុចរិតបាន អោយទទួលជឿ លើព្រះយេស៊ូវគ្រីស្ទ សំរាប់អោយបានការអត់ទោសនិងការលាងសំអាតពីបាប ហើយអោយបានបំពេញការល្អដែលពេញព្រះទ័យនិងសមរម្យចំពោះព្រះនេត្រទ្រង់។

យើងជឿថាជនទាំងអស់ ទោះជាគេបានរស់នៅក្នុងជីវិតកែរជាថ្មី ហើយបានញែកជីវិត គេទាំងស្រុងសំរាប់ព្រះក៏ដោយ អាចនឹងធ្លាក់ដាច់ចេញពីព្រះគុណនិងដាច់ចេញពីព្រះ និងគ្មាន សេចក្តីសង្ឃឹម ហើយនិងបាត់បង់អស់កល្បជានិច្ចលើកតែគេប្រែចិត្តពីការប្រព្រឹត្តអំពើបាបមកវិញ។

(ការបង្កើតក្នុងរូបភាពទ្រង់និងការទទួលខុសត្រូវក្នុងបែបចិត្តគំនិតក្នុងការរស់នៅៈ លោកុប្បត្តិ ១:២៦-២៧, ២:១៦-១៧, ចោទិយកាថា ២៨:១-២, ៣០:១៩, យ៉ូស្វេ ២៤:១៥, ទំនុកដំកើង ៨:៣-៥, អេសាយ ១:៨-១០,

យេរេមា ៣១:២៩-៣០, អេសេគាល ១៨:១-៤, មីកា ៦:៨, រ៉ូម ១:១៩-២០, ២:១-១៦, ១៤:៧-១២, កាឡាទី ៦:៧-៨។

ការឥតសមត្ថភាពក្នុងនិស្ស័យចាស់: យ៉ូប ១៤:៤, ១៥:១៤, ទំនុកដំកើង ១៤:១-៤, ៥១:៥, យ៉ូហាន ៣:៦, រ៉ូម ៣:១០-១២, ៥:១២-១៤, ២០, ៧:១៤-១៥

ព្រះគុណដោយឥតជំនួរអ្វីហើយនិងការប្រព្រឹត្តនៃជំនឿ: អេសេគាល ១៨:២៥-២៦, យ៉ូហាន ១:១២-១៣, ៣:៦, កិច្ចការ ៥:៣១, រ៉ូម ៥:៦-៨, ១៨, ៦:១៥-១៦, ២៣, ១០:៦-៨, ១១:២២, កូរិនថូសទី១ ២:៩-១៤, ១០:១-១២, កូរិនថូសទី២ ៥:១៨-១៩, កាឡាទី ៥:៦, អេភេសូរ ២:៨-១០, ភីលិព ២:១២-១៣, កូល៉ុស ១:២១-២៣, ធីម៉ូថេទី២ ៤:១០, ទីតុស ២:១១-១៤, ហេព្រើរ ២:១-៣, ៣:១២-១៥, ៦:៤-៦, ១០:២៦-៣១, យ៉ាកុប ២:១៨-២២, ពេត្រុសទី២ ១:១០-១១, ២:២០-២២)

## ៨ កាប្រែចិត្ត

៨ យើងជឿថាការប្រែចិត្ត ដែលមានភាពពិតប្រាកដនិងផ្លាស់ប្រែចិត្តគំនិតទាំងស្រុង ចំពោះអំពើបាប ដែលមានការទាក់ទងនឹងភាពទទួលស្គាល់កំហុសខ្លួនផ្ទាល់ ហើយនឹងការស្ម័គ្រ ចិត្តបែរចេញពីបាប គឺជំរូវដល់គ្រប់គ្នា ដែលដោយគោលបំណងនិងការប្រព្រឹត្តបានក្លាយទៅជាអ្នកមានបាបចំពោះព្រះ។ ព្រះវិញ្ញាណនៃព្រះប្រទានដល់គ្រប់គ្នាដែលនឹងប្រែចិត្តនូវជំនួយដ៏សប្បុរស ដល់ចិត្តដែលមានការនឹកស្តាយនិងសេចក្តីសង្ឃឹមក្នុងសេចក្តីមេត្តាករុណា ដែលគេអាចជឿដល់ការអត់ទោសបាបនិងជីវិតខាងវិញ្ញាណវិញ។

(របាក្សត្រទី២ ៧:១៤, ទំនុកដំកើង ៣២:៥-៦, ៥១:១-១៧, អេសាយ ៥៥:៦-៧, យេរេមា ៣:១២-១៤, អេសេគាល ១៨:៣០-៣២, ៣៣:១៤-១៦, ម៉ាកុស ១:១៤-១៥, លូកា ៣:១-១៤, ១៣:១-៥, ១៨:៩-១៤, កិច្ចការ ២:៣៨, ៣:១៩, ៥:៣១, ១៧:៣០-៣១, ២៦:១៦-១៨, រ៉ូម ២:៤, កូរិនថូសទី២ ៧:៨-១១, ថែស្សាឡូនិចទី១ ១:៩, ពេត្រុសទី២ ៣:៩)

## ៩ ការរាប់ជាសុចរិត ការកែប្រែជាថ្មី និងកាទទួលជាកូន

៩ យើងជឿថាការរាប់ជាសុចរិតគឺជាកិច្ចការរបស់ព្រះប្រកបដោយព្រះគុណនិងតាមផ្លូវច្បាប់ ដែលព្រះទ្រង់ផ្តល់ការអត់ទោសគ្រប់សព្វដល់គ្រប់អ្នកដែលទទួលស្គាល់កំហុស ហើយ និងការដោះលែងពេញទីអោយរួចពីទោសនៃអំពើបាបដែលបានប្រព្រឹត្ត ហើយនិងកាទទួលព្រមរាប់ថាជាសុចរិត ដល់អស់អ្នកជឿលើព្រះយេស៊ូវគ្រីស្ទហើយទទួលទ្រង់ទុកជាព្រះអម្ចាស់និងព្រះអង្គសង្គ្រោះ។

១០ យើងជឿថា ការកែប្រែជាថ្មីឬការកើតជាថ្មី គឺជាកិច្ចការប្រកបដោយព្រះគុណ របស់ព្រះ ដែលធ្វើឲ្យនិស្ស័យខាងចិត្តគំនិតចាស់នៃអ្នកជឿដែលប្រែចិត្តបានផ្លាស់ប្រែទៅជា ខាងវិញ្ញាណវិញ ហើយបង្កើតជាជីវិតខាងវិញ្ញាណពេញដោយជំនឿនិងការស្តាប់បង្គាប់។

១១ យើងជឿថា ការទទួលជាកូនគឺជាកិច្ចការប្រកបដោយព្រះគុណរបស់ព្រះដែល ធ្វើអោយអ្នកជឿដែលបានរាប់ជាសុចរិតនិងបានកែប្រែជាថ្មី បានកើតទៅជាកូនព្រះ។

១២ យើងជឿថាការរាប់ជាសុចរិត ការកែប្រែជាថ្មី និងការទទួលជាកូនគឺកើតព្រមគ្នា ក្នុងជីវិតនៃអ្នកស្វែងរកព្រះ ហើយគឺបានទទួលក្នុងលក្ខ័ណនៃជំនឿ ក្រោយពីមានការប្រែចិត្ត ហើយសំរាប់កិច្ចការនេះនិងសភាពនៃព្រះគុណ ព្រះវិញ្ញាណបរិសុទ្ធទ្រង់ជាអ្នកធ្វើជាទីបន្ទាល់។

(លូកា ១៨:១៤, យ៉ូហាន១:១២-១៣, ៣:៣-៨, ៥:២៤, កិច្ចការ ១៣-៣៩, រ៉ូម ១:១៧, ៣:២១-២៦, ២៨, ៤:៥-៩, ១៧-២៥, ៥:១, ១៦-១៩, ៦:៤, ៧:៦,៨:១, ១៥-១៧, កូរិនថូសទី១ ១:៣០, ៦:១១, កូរិនថូសទី២ ៥:១៧-២១, កាឡាទី ២:១៦-២១, ៣:១-១៤, ២៦, ៤:៤-៧, អេភេសូរ ១:៦-៧, ២:១, ៤-៥, ភីលិព ៣:៣-៩, កូល៉ុស ២:១៣,

ទីតុស ៣:៤-៧, ពេត្រុសទី១ ១:២៣, យ៉ូហានទី១ ១:៩, ៣:១-២, ៩, ៤:៧, ៥:១, ៩-១៣, ១៨)

## ១០ ការញែកគ្រប់ទាំងអស់ជាបរិសុទ្ធ

១៣ យើងជឿថាការញែកគ្រប់ទាំងអស់ជាបរិសុទ្ធគឺជាកិច្ចការរបស់ព្រះ បន្ទាប់ពីការកើតជាថ្មីមក ដែលអ្នកជឿបានទទួលការដោះលែងអោយរួចពីបាបដើមដំបូងឬភាពខូចបង់ ហើយបាននាំចូលទៅក្នុងភាពថ្វាយខ្លួនទាំងអស់ដាច់ដល់ព្រះ ហើយនិងការគោរពស្តាប់តាមដ៏បរិសុទ្ធនៃសេច ក្តីស្រលាញ់បង្កើតអោយបានគ្រប់លក្ខណ៍។

គឺជាការកើតឡើងដោយការលាងសំអាតដោយព្រះវិញ្ញាណបរិសុទ្ធ ដែលមានរួមមកជាការពិសោធ៏តែមួយនូវការលាងសំអាតចិត្តពីបាប និងការនៅជាប់ជាមួយការរស់នៅក្នុងវត្តមាននៃ ព្រះវិញ្ញាណបរិសុទ្ធ ហើយនិងការបង្កើនកំលាំងដល់អ្នកជឿសំរាប់ជីវិតរស់នៅនិងការបំរើព្រះ។

ការញែកទាំងអស់ជាបរិសុទ្ធបានប្រទានមកដោយសារព្រះលោហិតព្រះយេស៊ូវ បានធ្វេចេញជារូបរាងភ្លាមមួយរំពេចឡើងដោយសារជំនឿ បន្ទាប់ពីការថ្វាយខ្លួនដល់ព្រះ ហើយសំរាប់ កិច្ចការនេះនិងសភាពនៃព្រះគុណព្រះវិញ្ញាណបរិសុទ្ធទ្រង់ជាអ្នកធ្វើជាទីបន្ទាល់។

ការពិសោធន៍នេះក៏បានត្រូវស្គាល់តាមពាក្យនិមួយៗទៅតាមដំណាក់ផ្សេងៗដែរ ដូចជា "ភាពគ្រប់លក្ខណ៏នៃគ្រីស្ទាន" "សេចក្តីស្រឡាញ់ដ៏គ្រប់លក្ខណ៍ " "ចិត្តបរិសុទ្ធ" "ការលាងសំអាត ដោយព្រះវិញ្ញាណបរិសុទ្ធ" "ភាពពោរពេញដោយព្រះពរ" និង " ភាពបរិសុទ្ធនៃគ្រីស្ទាន "។

១៤ យើងជឿថាមានការប្លែកពីគ្នាយ៉ាងជាក់ស្តែងរវាងចិត្តបរិសុទ្ធនិងអាកប្បកិរិយាចាស់ ទុំ។ ចិត្តបរិសុទ្ធគឺកើតឡើងដោយភ្លាមៗ គឺជាលទ្ធផលនៃការញែកទាំងអស់ជាបរិសុទ្ធ រីឯអាកប្បកិរិយាចាស់ទុំគឺជាលទ្ធផលនៃការចំរើនលូតលាស់ក្នុងព្រះគុណ។

យើងជឿថាព្រះគុណនៃការញែកទាំងអស់ជាបរិសុទ្ធមានរួមបញ្ចូលសន្ទុះចិត្តឲ្យចំរើនលូតលាស់ក្នុងព្រះគុណ។ ប៉ុន្តែទោះជាដូច្នេះក៏ដោយ សន្ទុះចិត្តនេះត្រូវទទួលការថែទាំដោយ យកចិត្តទុកដាក់ ហើយនិងត្រូវប្រុងប្រយ័ត្នចំពោះការដំរូវនិងដំណើរនៃការលូតលាស់ខាងវិញ្ញាណ និងការកាន់តែប្រសើរឡើងខាងអាកប្បកិរិយានិងចរិយាសម្បត្តិអោយបានដូចជាព្រះគ្រីស្ទ។ បើគ្មានការខំប្រឹងខ្នះខ្នែងពីក្នុងចិត្តនេះទេ ទីបន្ទាល់របស់គេអាចចុះអន់ថយ ព្រះគុណកាន់តែរសាយ ហើយបាត់បង់ទៅ។

(យេរេមា ៣១:៣១-៣៤, អេសេគាល ៣៦:២៥-២៧, មាឡាគី ៣:២-២, ម៉ាថាយ ៣:១១-១២, លូកា ៣:១៦-១៧, យ៉ូហាន ៧:៣៧-៣៩, ១៤:១៥-២៣, ១៧:៦-២០, កិច្ចការ ១:៥, ២:១-៤, ១៥:៨-៩, រ៉ូម ៦:១១-១៣, ១៩,

៨:១-៤, ៨-១៥, ១២:១-២, កូរិនថូសទី២ ៦:១៤-៧:១, កាឡាទី ២:២០, ៥:១៦-២៥, អេភេសូរ ៣:១៤-២១,
៥:១៧-១៨, ២៥-២៧, ភីលិព ៣:១០-១៥, កូល៉ុស ៣:១-១៧, ថែស្សាឡូនិចទី១ ៥:២៣-២៤, ហេព្រើរ ៤:៩-
១១, ១០:១០-១៧, ១២:១-២, ១៣:១២, យ៉ូហានទី១ ១:៧, ៩)

("ភាពគ្រប់លក្ខណ៍នៃគ្រីស្ទាន" "សេចក្តីស្រឡាញ់ដ៏គ្រប់លក្ខណ៍": ចោទិយកថា ៣០:៦, ម៉ាថាយ ៥:៤៣-៤៨, ២២:៣៧-៤០, រ៉ូម ១២:៩-២១, ១៣:៨-១០, កូរិនថូសទី១ ១៣, ភីលិព ៣:១០-១៥, ហេព្រើរ ៦:១, យ៉ូហានទី១ ៤:១៧-១៨

"ចិត្តបរិសុទ្ធ": ម៉ាថាយ ៥:៨, កិច្ចការ ១៥:៨-៩, ពេត្រុសទី១ ១:២២, យ៉ូហានទី១ ៣:៣

"ការលាងសំអាតដោយព្រះវិញ្ញាណបរិសុទ្ធ": យេរេមា ៣១:៣១-៣៤, អេសេគាល ៣៦:២៥-២៧, ម៉ាឡាគី ៣:២-៣, ម៉ាថាយ ៣:១១-១២, លូកា ៣:១៦-១៧, កិច្ចការ ១:៥, ២:១-៤, ១៥:៨-៩

"ភាពពោរពេញដោយព្រះពរ": រ៉ូម ១៥:២៤

"ភាពបរិសុទ្ធនៃគ្រីស្ទាន": ម៉ាថាយ ៥:១-៧:២៩, យ៉ូហាន ១៥:១-១១, រ៉ូម ១២:១-១៥:៣, កូរិនថូសទី២ ៧:១, អេភេសូរ ៤:១៧-៥:២០, ភីលិព ១:៩-១១, ៣:១២-១៥, កូល៉ុស ២:២០-៣:១៧, ថែស្សាឡូនិចទី១ ៣:១៣, ៤:៧-៨, ៥:២៣, ធីម៉ូថេទី២ ២:១៩-២២, ហេព្រើរ ១០:១៩-២៥, ១២:១៤, ១៣:២០-២១, ពេត្រុសទី១ ១:១៥-១៦, ពេត្រុសទី២ ១:១-១១, ៣:១៨, យូដាស ២០-២១)

## ១១ ក្រុមជំនុំ

១៥ យើងជឿលើក្រុមជំនុំ ក្រុមដែលទទួលយកព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ សេចក្តីសញ្ញាដែលរាស្ត្ររបស់ព្រះបាទតាំងជាថ្មីក្នុងព្រះគ្រីស្ទ រូបកាយនៃព្រះគ្រីស្ទដែលបានហៅចូលមក រួមគ្នាដោយសារព្រះវិញ្ញាណបរិសុទ្ធតាមរយៈព្រះបន្ទូលព្រះ។

ព្រះទ្រង់ហៅតាំងក្រុមជំនុំសំរាប់បង្ហាញចេញជាជីវិតនៅក្នុងការរួបរួមគ្នានិងនៅក្នុងការប្រកបគ្នាជាមួយព្រះវិញ្ញាណ នៅក្នុងការថ្វាយបង្គំព្រះតាមរយៈការអធិប្បាយចែកចាយព្រះបន្ទូល ទទួលប្រត្តិបត្ត ពិធីបរិសុទ្ធផ្សេងៗ និងបំរើកិច្ចការក្នុងព្រះនាមទ្រង់ ដោយស្តាប់បង្គាប់ដល់ ព្រះគ្រីស្ទនិងការទទួលរ៉ាប់រងជាមួយគ្នាទៅវិញទៅមក។

ភារកិច្ចនៃក្រុមជំនុំនៅក្នុងពិភពលោកទាំងមូលគឺជាការបន្តកិច្ចការសង្គ្រោះរបស់ព្រះគ្រីស្ទនៅក្នុងព្រះចេស្តាព្រះវិញ្ញាណតាមរយៈការរស់នៅដោយបរិសុទ្ធ ការផ្សាយដំណឹងល្អ ការ បង្កើតសិស្ស និងការបំរើ។

ក្រុមជំនុំគឺជាហេតុការណ៍ជាក់ស្តែងក្នុងប្រវិត្តិសាស្ត្រ ដែលរៀបចំឡើងខ្លួនឯងនៅក្នុងរូបរាងយោលទៅតាមវប្បធម៌ កើតជាក្រុមជំនុំតំបន់ផងហើយជាអង្គការសាកលផង ញែកតាំងអ្នកដែលព្រះទ្រង់បានហៅសំរាប់កិច្ចការបំរើជាក់លាក់ណាមួយ។ ព្រះទ្រង់ហៅតាំងក្រុមជំនុំអោយរស់នៅក្រោមការគ្រប់គ្រងរបស់ទ្រង់ ក្នុងការរងចាំដោយរំភើបទូវការជួបជុំគ្នានៅពេលព្រះអម្ចាស់យេស៊ូវគ្រីស្ទយាងនិវត្តមកវិញ។

(និក្ខមនំ១៩:៣, យេរេមា ៣១:៣៣, ម៉ាថាយ ៨:១១, ១០:៧, ១៦:១៣-១៩, ១៦:២៤, ១៨:១៥-២០, ២៨:១៩-២០, យ៉ូហាន ១៧:១៤-២៦, ២០:២១-២៣, កិច្ចការ ១:៧-៨, ២:៣២-៤៧, ៦:១-២, ១៣:១, ១៤:២៣, រ៉ូម ២:២៨-២៩, ៤:១៦, ១០:៩-១៥, ១១:១៣-៣២, ១២:១-៨, ១៥:១-៣, កូរិនថូសទី១ ៣:៥-៩, ៧:១៧, ១១:១,

១១:១៧-៣៣, ១២:៣, ១២:១២-៣១, ១៥:២៦-៥០, កូរិនថូសទី២ ៥:១១-៦:១, កាឡាទី ៥:៦, ៥:១៣-១៥, ១៦:១-៥, ១៦:១៥, អេភេសូរ ៥:១-១៧, ៥:២៥-២៧, ភីលិព ២:១-១៦, ថែស្សាឡូនិចទី១ ៥:១-១២, ធីម៉ូថេ ៥:១៣, ហេព្រើរ ១០:១៩-២៥, ពេត្រុសទី១ ១:១-២, ១:១៣, ២:៥-១២, ២:២១, ៥:១-២, ៥:១០-១១, យ៉ូហានទី១ ៥:១៧, យូដាស ២៥, វិវរណៈ ៥:៩-១០)

## ១២ ពិធីជ្រមុជទឹក

១៦ យើងជឿថាពិធីជ្រមុចទឹកនៃគ្រីស្ទាន ដែលព្រះអម្ចាស់បានបង្គាប់មក គឺជាពិធី បរិសុទ្ធមួយ សំដែងអំពីការយល់ព្រមទទួលប្រយោជន៍នៃការប្រោសលោះរបស់ព្រះយេស៊ូវគ្រីស្ទ ដែលបានប្រទានដល់អ្នកជឿ ហើយនិងសំដែងអំពីការប្រកាសប្រាប់អំពីជំនឿរបស់ខ្លួនក្នុងព្រះ

យេស៊ូវគ្រីស្ទទុកជាព្រះអង្គសង្គ្រោះ ហើយនិងគោលដៅពេញលេញនៃការស្តាប់បង្គាប់ក្នុងសេចក្តី បរិសុទ្ធនិងសេចក្តីសុចរិត។

ពិធីជ្រមុចទឹកដោយគ្រាន់តែជាសញ្ញានៃការចុះខសញ្ញាជាថ្មីនោះ ក្មេងតូចៗអាចទទួល ពិធីជ្រមុចទឹកនេះបាន ដោយយោលទៅតាមសំណូមនៃមាតាបិតាឬអ្នកអាណាព្យាបាលដែល ត្រូវធានាអ៉ាប់រងផ្តល់នូវការហ្វឹកហ្វឺនចាំបាច់ដល់កូនទាំងនោះ។

ពិធីជ្រមុចទឹកអាចប្រារព្ធធ្វើបានតាមបែបប្រស់ទឹក ស្រោចទឹក ឬក៏ជ្រមុចទៅក្នុងទឹក ដោយ យោងទៅតាមការជ្រើសរើសនៃអ្នកដែលត្រូវទទួល។

(ម៉ាថាយ ៣:១-៧, ២៨:១៦-២០, កិច្ចការ ២:៣៧-៤១, ៨:៣៥-៣៩, ១០:៤៤-៤៨, ១៦:២៥-៣៥, ១៩:១-៦, រ៉ូម ៦:៣-៤, កាឡាទី ៣:២៦-២៨, កូលុស ២:១២, ពេត្រុសទី១ ៣:១៨-២២)

## ១៣ ពិធីលៀងព្រះអម្ចាស់

១៧ យើងជឿថាការរំលឹកនិងការព្រមព្រៀងគ្នាទទួលពិធីលៀងព្រះអម្ចាស់ដែលចាប់ តាំងអនុវត្តឡើងដោយព្រះអម្ចាស់នៃយើងហើយនឹងព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ជាពិធី សំខាន់នៅក្នុងសញ្ញាថ្មី ជាការសំដែងអំពីការថ្វាយជីវិតរបស់ព្រះអង្គ ដោយតាមរយៈគុណសម្បត្តិ នេះហើយដែលអ្នកជឿមានជីវិតនិងសេចក្តីសង្គ្រោះ ហើយនិងសេចក្តីសន្យានូវគ្រប់ទាំងព្រះពរ ខាងវិញ្ញាណក្នុងព្រះគ្រីស្ទ។ គឺជាការប្លែកសំរាប់អ្នកដែលរៀបចំខ្លួនទទួលក្នុងការអរព្រះគុណ សមរម្យទៅតាមន័យនៃពិធីនេះ ហើយដោយទទួលការនេះគឺគេសំដែងរំលឹកអំពីការសុគតនៃព្រះ អម្ចាស់រហូតដល់ទ្រង់យាងនិវត្តមកវិញម្តងទៀត។ គឺជាពិធីលៀងដោយព្រមព្រៀងគ្នា គឺសំរាប់ តែអ្នកដែលមានជំនឿក្នុងព្រះគ្រីស្ទ ហើយមានសេចក្តីស្រឡាញ់ដល់អ្នកបរិសុទ្ធដែលគួរត្រូវហៅ អោយចូលរួមក្នុងពិធីនេះ។

(និក្ខមនំ ១២:១-១៤, ម៉ាថាយ ២៦:២៦-២៩, ម៉ាកុស ១៤:២២-២៥, លូកា ២២:១៧-២០, យ៉ូហាន ៦:២៨-៥៨, កូរិនថូសទី១ ១០:១៤-២១, ១១:២៣-៣២)

## ១៤ ការប្រោសអោយជាដែលមកពីព្រះ

១៨ យើងជឿទៅលើគោលទិន្នអំពីការប្រោសអោយជាដែលមកពីព្រះក្នុងព្រះគម្ពីរ ហើយជំរុញក្រុមជំនុំយើងអោយខំអធិស្ឋានដោយជំនឿសំរាប់ការប្រោសអ្នកឈឺអោយជា។ (មធ្យោបាយនិងការអនុវត្តន៍នៃការសក្តិសិទ្ធនេះនៅពេលដែលចាំបាច់នោះមិនគួរអោយប្រកែកទេ)។ យើងក៏ជឿថាព្រះទ្រង់ព្យាបាលតាមមធ្យោបាយនៃវិជ្ជាពេទ្យដែរ។

(ពង្សាវតារក្សត្រទី២ ៥:១-១៩, ទំនុកដំកើង ១០៣:១-៥, ម៉ាថាយ ២:២៣-២៤, ៩:១៨-៣៥, យ៉ូហាន ៤:៤៦-៥៤, កិច្ចការ ៥:១២-១៦, ៩:៣២-៤២, ១៤:៨-១៥, កូរិនថូសទី១ ១២:៤-១១, កូរិនថូសទី២ ១២:៧-១០, យ៉ាកុប ៥:១៣-១៦)

## ១៥ ការយាងនិវត្តលើកទី២នៃព្រះគ្រីស្ទ

១៩ យើងជឿថាព្រះអម្ចាស់យេស៊ូវគ្រីស្ទនឹងយាងនិវត្តមកវិញម្តងទៀត ថាយើងដែលនៅរស់ពេលដែលទ្រង់យាងនិវត្តមកវិញនិងមិនទៅមុនអ្នកដែលបានដេកក្នុងព្រះគ្រីស្ទយេស៊ូវទេ តែថាបើយើងនៅជាប់ក្នុងទ្រង់ យើងនឹងឡើងទៅជួបជុំគ្នាជាមួយអ្នកបរិសុទ្ធដែលបានឡើងទៅមុនទៅជួបព្រះអម្ចាស់ក្នុងលំហរអាកាស ដើម្បីយើងទៅនៅជាមួយព្រះអម្ចាស់រហូតតទៅ។

(ម៉ាថាយ ២៥:៣១-៤៦, យ៉ូហាន ១៤:១-៣, កិច្ចការ ១:៩-១១, ភីលិព ៣:២០-២១, ថែស្សាឡូនិចទី១ ៤:១៣-១៨, ទីតុស ២:១១-១៤, ហេព្រើរ ៩:២៦-២៨, ពេត្រុសទី២ ៣:៣-១៥, វិវរណៈ ១:៧-៨, ២២:៧-២០)

## ១៦ ការរស់ឡើងវិញ ការជំនុំជំរះ និងវាសនា

២០ យើងជឿអំពីការរស់ឡើងវិញនៃពួកអ្នកស្លាប់ ថារូបកាយរបស់គេទាំងអ្នកសុចរិតហើយនិងទុច្ចរិតនឹងត្រូវប្រោសអោយរស់មានជីវិតឡើងវិញហើយជួបជុំជាមួយវិញ្ញាណរបស់គេ "អ្នកដែលបានប្រព្រឹត្តល្អនឹងទទួលការរស់ឡើងវិញខាងឯជីវិតអស់កល្បជានិច្ច ហើយអ្នកដែល បានប្រព្រឹត្តអាក្រក់នឹងទទួលការរស់ឡើងវិញខាងឯទុក្ខទោសអស់កល្បជានិច្ច"។

២១ យើងជឿអំពីការជំនុំជំរះក្នុងពេលអនាគតដែលគ្រប់គ្នានឹងឈរនៅចំពោះព្រះទទួលសេចក្តីជំនុំជំរះយោងទៅតាមការដែលខ្លួនបានប្រព្រឹត្តនៅក្នុងជីវិតនេះ។

២២ យើងជឿថាជីវិតដ៏ពេញដោយសិរីល្អនិងភាពអស់កល្បជានិច្ចបានត្រូវធានាផ្តល់អោយដល់អស់អ្នកណាដែលបានសង្គ្រោះដោយជឿនិងស្តាប់បង្គាប់តាមព្រះយេស៊ូវគ្រីស្ទជាព្រះ អម្ចាស់ ហើយថាអ្នកដែលមិនប្រែចិត្តនៅទីចុងបំផុតនឹងទទួលការរងទុក្ខអស់កល្បជានិច្ចនៅក្នុង នរក។

(លោកុប្បត្តិ ១៨:២៥, សាំយូអែលទី១ ២:១០, ទំនុកដំកើង ៥០:៦, អេសាយ ២៦:១៩, ដានីយ៉ែល ១២:២-៣, ម៉ាថាយ ២៥:៣១-៤៦, ម៉ាកុស ៩:៤៣-៤៨, លូកា ១៦:១៩-៣១, ២០:២៧-៣៨, យ៉ូហាន ៣:១៦-១៨, ៥:២៥-២៩, ១១:២១-២៧, កិច្ចការ ១៧:៣០-៣១, រ៉ូម ២:១-១៦, ១៤:៧-១២, កូរិនថូសទី១ ១៥:១២-៥៨, កូរិនថូសទី២ ៥:១០, ថែស្សាឡូនិចទី២ ១:៥-១០, វិវរណៈ ២០:១១-១៥, ២២:១-១៥)។